# English for Study in Australia
# កម្មវិធីភាសាអង់គ្លេសសម្រាប់ការសិក្សានៅប្រទេសអូស្ត្រាលី

## LESSON 5 – College Orientation
## មេរៀនទី៥ ៖ ការតម្រង់ទិសចូលមហាវិទ្យាល័យ

**STUDY NOTES**
ឯកសារជំនួយមេរៀន

តួអង្គ

Rocky:
រ៉ុកឃី ៖ ជាភ្ញៀវទេសចរប្រុសវ័យក្មេង ហើយមកប្រទេសអូស្ត្រាលីជាលើកទី១។
Angel:
អែនជល ៖ ជានិស្សិតបរទេស ហើយមកប្រទេសអូស្ត្រាលីជាលើកទីមួយ១។
Katie:
ខេតធី ៖ ជានិស្សិតបរទេស មកប្រទេសអូស្ត្រាលីជាលើកទី១។
Anne Dunleavy:
អេន ដាន់លីវី ៖ នាយកសិក្សា នៅសាលាភាសាអង់គ្លេសអន្តរជាតិ។
Marion:
មារៀន ៖ ជាគ្រូបង្រៀន/អ្នកសម្ភាសន៍ នៅសាលាភាសាអង់គ្លេសអន្តរជាតិ។

សាច់រឿង

រ៉ុកឃី មកចូលរួមវគ្គផ្តល់ព័ត៌មានណែនាំតម្រង់ទិសដៅនៅសាលារៀន ELICOS។ លោកមានការភ្ញាក់ផ្អើលលាយនឹងក្តីរំភើប នៅពេលឃើញអែនជល និងខេតធី ដែលលោកបានជួបនៅព្រលានយន្តហោះមែលប៊ិនបានមករៀននៅសាលាជាមួយគ្នា។ ពួកគេទាំងអស់គ្នា ត្រូវឆ្លងកាត់ការធ្វើតេស្តដើម្បីវាស់ស្ទង់កម្រិតសមត្ថភាពភាសាអង់គ្លេស រួមនឹងការជួបសម្ភាសន៍ដោយផ្ទាល់ជាមួយនឹងគ្រូបង្រៀនម្នាក់។

ភាសា

ខាងក្រោមនេះ ជាវាក្យសព្ទមួយចំនួន ដែលលោកអ្នកជួបប្រទះនៅក្នុងការសិក្សា នៅតាមសាលារៀនសាកលវិទ្យាល័យ និងមហាវិទ្យាល័យ។

| | |
|---|---|
| Chancellor | សាកលវិទ្យាធិការ |
| Vice-Chancellor | សាកលវិទ្យាធិការរង |


© RadioAustralia/AMES 2008
ABC Radio Australia

| | |
|---|---|
| Director of Studies | នាយកសិក្សាមហាវិទ្យាល័យ ELICOS |
| Head or Dean | ព្រឹទ្ធបុរសមហាវិទ្យាល័យ ឬប្រធានដេប៉ាតឺម៉ង់ |
| Principal | នាយកសាលាបឋមសិក្សា ឬវិទ្យាល័យ |
| Administration | ការិយាល័យរដ្ឋបាលឬស្ថាប័នអប់រំ ដែលមានការងារទាក់ទងនឹងឯកសារសិក្សា និងដំណើរការសិក្សារបស់សិស្ស |
| Campus | សាខាមហាវិទ្យាល័យ ឬសាកលវិទ្យាល័យ |
| Library | បណ្ណាល័យ |
| ILC (Independent Learning Centre) | មជ្ឈមណ្ឌលស្វ័យសិក្សា។ ជាធម្មតា មានទីតាំងនៅក្នុងបណ្ណាល័យ ហើយកន្លែងនេះ គឺសម្រាប់ការសិក្សារបស់សិស្សម្នាក់ៗ។ កន្លែងនេះអាចមានកុំព្យូទ័រ និងបន្ទប់ប្រអប់សម្រាប់ស្តាប់សំឡេង។ |
| Student Lounge | បរិវេណសម្រាប់ពេលសម្រាក ។ មហាវិទ្យាល័យភាគច្រើន មានបរិវេណសម្រាប់ពេលសម្រាក ដែលអាចសម្រាកនៅចន្លោះម៉ោងសិក្សា ឬអាចកំដៅ និងទទួលទានអាហារថ្ងៃត្រង់។ |
| Cafeteria/canteen | ហាងកាហ្វេ/កង់ទីន ។ មហាវិទ្យាល័យ និងសាកលវិទ្យាល័យធំៗ មានកន្លែងដែលនិស្សិត អាចទិញម្ហូបអាហារឆ្អិនស្រាប់ក្នុងតម្លៃមួយសមរម្យ។ ប៉ុន្តែកន្លែងទាំងអស់នេះ ខុសគ្នាពីភោជនីយដ្ឋាន ត្រង់ថា ហាងកាហ្វេ/កង់ទីនពុំមានសេវាបម្រើតាមតុទេ។ និស្សិតអាចជ្រើសរើស និងបង់ថ្លៃម្ហូបអាហារនៅកន្លែងគិតលុយ និងលើកអាហារទៅបរិភោគនៅតាមតុវែង(ដែលរៀបជាជួរៗ)។ |

ABC Radio Australia

**EXERCISES**
លំហាត់

១ វាក្យសព្ទសំខាន់ៗ


© RadioAustralia/AMES 2008

សូមផែកអត្ថន័យ និងការបញ្ចេញសំឡេងនៃពាក្យទាំងអស់នេះនៅក្នុងវចនានុក្រមរបស់លោកអ្នក ៖

| | | |
|---|---|---|
| academic | coincidence | director |
| information | interview | module |
| orientation | placement | post code |
| purpose | requirement | Schedule |
| semester | session | Test |

២ ការហាត់រៀនភាសា លំហាត់គំរូ - តេស្តស្ទង់កម្រិតសមត្ថភាពភាសាអង់គ្លេស

ដើម្បីអាចចូលរៀនក្នុងវគ្គសិក្សាណាមួយនោះ លោកអ្នកត្រូវឆ្លងកាត់ការធ្វើតេស្តដើម្បីស្ទង់កម្រិតសមត្ថភាពភាសាអង់គ្លេសជាមុនសិន។ សូមកត់ចំណាំថា ការណែនាំក្នុងការធ្វើតេស្ត ជាទូទៅ សរសេរជាភាសាអង់គ្លេស (ដូចខាងក្រោមនេះ)។

Choose the word that best fits each space in the text below.

ចូរជ្រើសពាក្យដែលសាកសមបំផុតសម្រាប់ដាក់ទៅក្នុងចន្លោះនៃអត្ថបទក្នុងប្រអប់ខាងក្រោម។

Cross one box for each number, eg: ☒ សូមគូសខ្វែងក្នុងប្រអប់មួយនៃសម្រាប់លេខនីមួយៗ។ ឧទាហរណ៍ ☒

**ELICOS Orientation**

Here is an example of the schedule for an ELICOS college orientation session. First you'll be ___1____ to the Director of Studies or their representative. You'll sit for a reading and a writing test, each ___2____ about thirty minutes duration. You'll have an individual interview with a teacher, who will ___3____ your details and test your listening and speaking levels. The assessment you receive for your tests will determine the class in ___4____ you are placed.

After a short break, you'll be ___5____ a tour of the school, taking in the classrooms, the library, the student lounge and other facilities. Then you'll have an information session where you'll learn about your course as well as your rights and responsibilities. Guest speakers are often asked ___6____ these sessions to inform you about services such as banking and weekend student activities.

| | | | | |
|---|---|---|---|---|
| 1. | ☐ meet | ☐ introduced | ☐ met | ☐ talked |
| 2 | ☐ of | ☐ in | ☐ along | ☐ by |
| 3. | ☐ receive | ☐ listen | ☐ talk | ☐ take |
| 4 | ☐ which | ☐ where | ☐ what | ☐ how |
| 5 | ☐ taken | ☐ given | ☐ seen | ☐ shown |


© RadioAustralia/AMES 2008

6. ☐ over ☐ for ☐ to ☐ at

៣ ឧបសគ្គក្នុងការប្រើភាសា

ស្វរសំឡេង / I / ។ សូមហាត់រៀនបញ្ចេញសំឡេងពាក្យនេះឱ្យបានឮ ៖

**“Let’s look at the library after lunch.”**

៤ អាសយដ្ឋានអ៊ីនធើរណិតដែលមានប្រយោជន៍

| | |
|---|---|
| ប្រព័ន្ធនៃការធ្វើតេស្តភាសាអង់គ្លេសជាអន្តរជាតិ | http://www.ielts.org/candidates/default.aspx |
| ការធ្វើតេស្តភាសាអង់គ្លេសដែលជាភាសាបរទេស | http://www.ets.org/portal/site/ets/menuitem.fab2360b1645a1de9b3a0779f1751509/?vgnextoid=69c0197a484f4010VgnVCM10000022f95190RCRD |
| ការធ្វើតេស្តភាសាអង់គ្លេសសម្រាប់ទំនាក់ទំនងអន្តរជាតិ | http://www.ets.org/portal/site/ets/menuitem.fab2360b1645a1de9b3a0779f1751509/?vgnextoid=06cfd898c84f4010VgnVCM10000022f95190RCRD |
| គំរូនៃការផ្តល់ព័ត៌មានណែនាំតម្រង់ទិសដៅនៅសកលវិទ្យាល័យ | http://www.services.unimelb.edu.au/orientation/undergrad/index.html |
| មជ្ឈមណ្ឌលស្វ័យសិក្សា | www.virtualilc.com.au |

ចម្លើយលំហាត់ទី២: 1) introduced 2) of 3) take 4) which 5) given 6) to

ABC Radio Australia


© RadioAustralia/AMES 2008